# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបុណ្យរោយផេះនៅព្រះសហគមន៍សន្តយ៉ូសែប
# ផ្សារតូច ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០

## ព្រះអង្គបានរងទុក្ខលំបាកដើម្បីប្រមូលទុក្ខលំបាករបស់យើង

**អត្ថបទទី១៖ យ៉ូអែល ២,១២-១៨**

ចូរវិលមករកព្រះអម្ចាស់ ជាព្រះរបស់អ្នករាល់គ្នាវិញ ដ្បិតព្រះអង្គតែងតែប្រណីសន្ដោស ព្រះអង្គមានព្រះហឫទ័យអាណិតអាសូរ ព្រះអង្គមានព្រះហឫទ័យអត់ធ្មត់ ពោរពេញដោយព្រះហឫទ័យមេត្តាករុណា ព្រះអង្គមិនសព្វព្រះហឫទ័យដាក់ទោសទេ។ យអ ២,១៣

**អត្ថបទទី២៖ កូរិនថូសទី២ ៥,២០-៦,២**

ព្រះគ្រីស្តគ្មានបាបទាល់តែសោះ តែព្រះជាម្ចាស់បានធ្វើឲ្យព្រះអង្គទៅជាតួបាបសម្រាប់យើង ដើម្បីប្រោសយើងឲ្យបានសុចរិតរួមជាមួយព្រះគ្រីស្តដែរ។ ២ករ ៥,២១

**ដំណឹងល្អ៖ ម៉ាថាយ ៦,១-៦.១៦-១៨**

រីឯអ្នកវិញ កាលណាដៃស្តាំអ្នកធ្វើទាន មិនបាច់ឲ្យដៃឆ្វេងដឹងឡើយ ដើម្បីឲ្យទានរបស់អ្នកនៅស្ងាត់កំបាំង ហើយព្រះបិតារបស់អ្នក ទតឃើញអំពើដែលអ្នកធ្វើនៅក្នុងទីស្ងាត់កំបាំង ទ្រង់នឹងប្រទានរង្វាន់មកអ្នកវិញ។ មថ ៦,៣-៤

បងប្អូនជាទីស្រឡាញ់!

នៅក្នុងគម្ពីរដំណឹងល្អ យើងបានស្តាប់បីដងព្រះយេស៊ូបានណែនាំឲ្យយើងធ្វើទាន អធិដ្ឋាន និងតមអាហារ ដោយធ្វើនៅក្នុងរបៀបស្ងៀមស្ងាត់។ នៅក្នុងអាថ៌កំបាំង ដោយដឹងថាព្រះបិតាទតមើលឃើញ និងព្រះបិតាប្រទានអ្វីៗទាំងអស់ដែលយើងត្រូវការ។ ឆ្នាំ២០២០នេះ ជាសម័យដែលយើងចូលចិត្តផ្សព្វផ្សាយ ចូលចិត្តបង្ហាញ អំពីស្នាដៃរបស់យើង អំពីសកម្មភាពរបស់យើង តាមបណ្តាញផ្សព្វផ្សាយសង្គមថ្មីៗ។ អ្វីដែលព្រះយេស៊ូមានព្រះបន្ទូលថ្ងៃនេះ វាផ្ទុយនឹងទម្លាប់របស់យើងសព្វថ្ងៃ ផ្ទុយនឹងអ្វីៗទាំងអស់ដែលយើងសប្បាយចិត្តក្នុងការប្រកាស បង្ហាញសម្តែង គ្រប់សកម្មភាពដែលយើងបានធ្វើ ទាំងការអធិដ្ឋាន ទាំងការតបអាហារ ទាំងរបៀបដែលយើងជួយអ្នកដទៃ។

រដូវ៤០ថ្ងៃនេះ ជាពេលវេលាមួយដើម្បីចូលយ៉ាងជ្រៅនៅក្នុងជីវិតរបស់យើងជាគ្រីស្តបរិស័ទ នៅក្នុងជីវិតរបស់យើងជាសាវ័ករបស់ព្រះយេស៊ូគ្រីស្ត។ អត្ថបទទីពីរ ជាអ្វីដែលសម្តេចប៉ាបបានដកស្រង់ដើម្បីអប់រំណែនាំយើងក្នុងរដូវ៤០ថ្ងៃនេះ "**យើងសូមអង្វរបងប្អូន នៅក្នុងព្រះនាមព្រះគ្រីស្តថា ទុកឲ្យព្រះជាម្ចាស់សម្រុះសម្រួលបងប្អូនឲ្យជានានឹងព្រះអង្គវិញទៅ**"។ នៅក្នុង៤០ថ្ងៃខាងមុខនេះ យើងត្រូវតែទូលអង្វរដើម្បីឲ្យយើងរួមគ្នាទទួលការសម្រុះសម្រួលរួមជាមួយ

ព្រះជាម្ចាស់ ដើម្បីទៅជាមនុស្សថ្មី។ នេះជាពេលវេលាមួយដែលណែនាំឲ្យយើងទៅជាមនុស្សថ្មី យើងត្រូវតែអរគុណព្រះសហគមន៍ អរព្រះគុណព្រះជាម្ចាស់ដែលបានប្រទានពេលវេលានេះ ដើម្បីចូល ដើម្បីស្តាប់ សាជាថ្មីអំពីដំណឹងល្អរបស់ព្រះអង្គ។ ដំណឹងល្អដែលយើងនឹងស្តាប់ នៅក្នុង៥០ថ្ងៃខាងមុខនេះ គឺជាដំណឹងល្អដែលណែនាំឲ្យយើងយល់ថាពិតមែនព្រះយេស៊ូរងទុក្ខលំបាក ពិតមែនព្រះយេស៊ូសោយទិវង្គត ពិតមែនព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ នេះជាអាថ៌កំបាំងនៃជំនឿរបស់យើង ប៉ុន្តែនេះជាអ្វីដែលយើងរស់នៅជាមួយព្រះយេស៊ូ ពេលយើងថារួមស្លាប់រួមរស់ជាមួយព្រះយេស៊ូ។ ៥០ថ្ងៃដែលយើងមានខាងមុខនេះ ជាពេលវេលាដើម្បីឲ្យយើងប្រកាសសាជាថ្មី ដំណឹងល្អដ៏អស្ចារ្យគឺព្រះយេស៊ូយាងមកដើម្បីសង្គ្រោះយើង ព្រះអង្គបានរងទុក្ខលំបាកដើម្បីប្រមូលទុក្ខលំបាករបស់យើង ព្រះយេស៊ូបានសោយទិវង្គតដោយសារអំពើបាបរបស់យើង និងព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញដើម្បីឲ្យយើងទាំងអស់ទទួលជីវិតថ្មីអស់កល្បជានិច្ច។ នេះជាដំណឹងល្អ ឲ្យយើងធ្វើជាគ្រីស្តបរិស័ទនៅពេលយើងប្រកាសជំនឿរបស់យើង។

ក្នុងឆ្នាំ២០២០នេះ សម្តេចប៉ាបបានអញ្ជើញយើងឲ្យយើងជាគ្រីស្តបរិស័ទចូលនៅក្នុងអាថ៌កំបាំងនៃព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ នៃពិធីបុណ្យចម្លងដើម្បីរួមគ្នាយើងមើលឃើញព្រះយេស៊ូនៅលើឈើឆ្កាង ដើម្បីណែនាំឲ្យព្រះយេស៊ូសង្គ្រោះយើង។ មើលឃើញព្រះយេស៊ូនៅលើឈើឆ្កាង ដើម្បីមើលឃើញរបៀបដែលព្រះយេស៊ូរំដោះយើង ទទួលអគ្គសញ្ញាលើកលែងទោសដោយយល់ថាពិតមែន តាមរយៈអគ្គសញ្ញាលើកលែងទោសគឺព្រះបិតាដែលស្រឡាញ់យើងយ៉ាងខ្លាំង ដែលមានព្រះហឫទ័យប្រណីសន្តោសណែនាំឲ្យយើងចូលនៅក្នុងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ ដើម្បីរស់នៅជាមនុស្សថ្មី ដើម្បីរំដោះយើងពីអំពើបាបទាំងអស់ ពីកំហុសយើងទាំងអស់ ដើម្បីទៅជាមនុស្សថ្មីយ៉ាងពិតប្រាកដ។ មើលព្រះលោហិតដែលហូរចេញពីទ្រូងព្រះអង្គ ដើម្បីលាងជំរះយើងឲ្យយើងកើតសាជាថ្មី នេះជាពេលវេលាមួយដើម្បីចូលនៅក្នុងជីវិតថ្មីពិតមែន។

ឆ្នាំនេះ យើងមានជិត៨០នាក់នៅក្នុងភូមិភាគភ្នំពេញដែលទទួលជំហានទីពីរសប្តាហ៍នេះ និងទទួលអគ្គសញ្ញាជ្រមុជទឹកនៅរាត្រីបុណ្យចម្លងខាងមុន។ ៨០នាក់ ដែលមានបទពិសោធន៍រួមស្លាប់រួមរស់ជាមួយព្រះយេស៊ូនៅក្នុងអគ្គសញ្ញាជ្រមុជទឹក។ សម្រាប់យើងទាំងអស់ក៏ដូចគ្នាដែរ ឲ្យយើងរួមស្លាប់នឹងអំពើបាបរបស់យើង រួមស្លាប់នឹងតណ្ហារបស់យើង ដើម្បីរួមរស់ជាមួយជីវិតថ្មីជាមួយព្រះយេស៊ូនៅខាងមុខនេះ។ ចូលនៅក្នុងជីវិតរបស់ព្រះយេស៊ូយ៉ាងពិតប្រាកដ ដោយសម្លឹងមើលព្រះយេស៊ូនៅលើឈើឆ្កាង។ កែប្រែចិត្តគំនិតជារឿងបន្ទាន់ ព្រះយេស៊ូយាងមកដើម្បី

សង្គ្រោះយើងបន្ទាន់ឲ្យយើងកែប្រែចិត្តគំនិតបន្ទាន់ដែរ។ យើងដឹងហើយថា ជីវិតរបស់យើងនៅលើផែនដីនេះមិនទៀងទាត់ទេ ម្សិលមិញយើងគ្មានជំងឺអ្វីសោះ ថ្ងៃនេះយើងឆ្លងជំងឺ ថ្ងៃស្អែកយើងស្លាប់។ ទទួលការសង្គ្រោះ និងជាពិសេសកែប្រែចិត្តគំនិតជារឿងបន្ទាន់នៅក្នុងជីវិតរបស់យើង ដោយចាប់ផ្តើមពីពេលនេះតទៅចូលនៅក្នុងការសន្ទនាជាមួយព្រះជាម្ចាស់ ជាពិសេសតាមរយៈការអធិដ្ឋាន។

រដូវ៤០ថ្ងៃ ជាពេលវេលាដើម្បីអធិដ្ឋាន មិនមែនអធិដ្ឋាននៅពេលយើងចូលព្រះវិហារយូរៗម្តង ជារៀងរាល់ថ្ងៃក្នុងរដូវ៤០ថ្ងៃនេះឲ្យយើងយកពេលដើម្បីអធិដ្ឋាន។ មានន័យថា ដើម្បីសម្លឹងមើលព្រះជាម្ចាស់ដែលជាព្រះបិតារបស់យើង ដើម្បីទុកឲ្យព្រះជាម្ចាស់ដែលជាព្រះបិតារបស់យើងសម្លឹងមើលខ្ញុំ មានន័យថាយើងសម្លឹងមើលគ្នាទៅវិញទៅមក ដោយស្តាប់គ្នាទៅវិញទៅមក។ យើងដឹងថា ថ្ងៃនេះព្រះបិតាមានព្រះបន្ទូលដើម្បីសង្គ្រោះខ្ញុំ ខ្ញុំធ្វើដូចម្តេចដើម្បីទទួលព្រះបន្ទូលនេះនៅក្នុងជីវិតខ្ញុំ និងរស់នៅតាមព្រះបន្ទូលក្នុងជីវិតប្រចាំថ្ងៃរបស់ខ្ញុំ។ នេះជាពេលវេលាដើម្បីទទួលការសង្គ្រោះបន្ទាន់ជាមួយព្រះជាម្ចាស់ដែលស្រឡាញ់យើងយ៉ាងខ្លាំង។

សព្វថ្ងៃ យើងទទួលព័ត៌មានច្រើនមានទាំងព័ត៌មានពិតនិងព័ត៌មានមិនពិត យើងត្រូវការពិនិត្យមើលអ្វីដែលយើងបានទទួលនៅក្នុងទំនាក់ទំនងជាមួយបងប្អូន នៅក្នុងរបៀបដែលយើងអាចទទួលព័ត៌មានទាំងអស់ ដើម្បីរកឃើញព្រះហឫទ័យរបស់ព្រះជាម្ចាស់។ សព្វថ្ងៃ ព្រះជាម្ចាស់មានវត្តមាននៅក្នុងព្រះសហគមន៍ នៅក្នុងពិភពលោក ដើម្បីណែនាំឲ្យយើងរួមរស់នៅក្នុងជីវិតថ្មីដែលព្រះជាម្ចាស់ប្រទានឲ្យ។ យើងដឹងថា ជីវិតយើងមិនទទួលពីយើងផ្ទាល់ យើងទទួលពីព្រះជាម្ចាស់ សេចក្តីសុខយើងមិនទទួលដោយសារស្នាដៃរបស់យើងផ្ទាល់ សេចក្តីសុខនិងអំណរសប្បាយយើងបានទទួលលុះត្រាតែ យើងទុកឲ្យព្រះជាម្ចាស់ធ្វើការនៅក្នុងជីវិតរបស់យើងប្រចាំថ្ងៃ។ ហេតុនេះហើយ ឲ្យយើងគិតយើងធ្វើដូចម្តេចដើម្បីសន្ទនាជាមួយព្រះជាម្ចាស់ ពីដើមព្រះជាម្ចាស់បានបង្កើតការសន្ទនារវាងមនុស្សយើងនិងព្រះអង្គ ព្រះអង្គដើរតាមយើង ព្រះអង្គបានចងសម្ពន្ធមេត្រីថ្មីជាមួយមនុស្សយើង។ ថ្ងៃនេះ ព្រះអង្គបានចងសម្ពន្ធមេត្រីថ្មីជាមួយយើងថែមទៀត ដើម្បីឲ្យជីវិតរបស់យើងទៅជាជីវិតអស្ចារ្យដ៏ពិតប្រាកដ ដោយសារយើងដឹងថាព្រះយេស៊ូសោយទិវង្គត និងព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ដើម្បីណែនាំឲ្យខ្ញុំចូលនៅក្នុងជីវិតរបស់ព្រះអង្គអស់កល្បជានិច្ច។

ហេតុនេះហើយ សរុបមកឲ្យយើងយល់ថា យើងធ្វើដូចម្តេចដើម្បីចែករំលែកទ្រព្យសម្បត្តិដ៏ពិសេសដែលយើងបានទទួល។ ដំណឹងល្អព្រះយេស៊ូមានជីវិតសព្វថ្ងៃ ទ្រព្យសម្បត្តិដែលយើងមាននៅក្នុងដៃរបស់យើង សេចក្តីស្រឡាញ់ដែលយើងមាន កម្លាំងដែលយើងមាន សេចក្តី

សង្ឃឹមដែលយើងមាន ដើម្បីណែនាំឲ្យយើងយល់ថាសង្គមរបស់យើងយកសមត្ថភាពជាអាទិភាព សង្គមរបស់យើងមានសមត្ថភាពដើម្បីមើលបងប្អូនដែលខ្វះខាត មើលបងប្អូនដែលគ្មានសេចក្តីសង្ឃឹម មើលកូនក្មេងដែលគ្មានអ្វីសោះនៅក្នុងជីវិតរបស់គេ...។ យើងជាគ្រីស្តបរិស័ទ យើងមិនអាចរស់នៅដូចគេឯង លក្ខខណ្ឌរបស់យើងគឺអធិដ្ឋាន ចែករំលែកជាមួយបងប្អូនឯទៀតៗជាពិសេសសេចក្តីសង្ឃឹមនិងជំនឿដែលយើងបានទទួលពីព្រះជាម្ចាស់។ ឲ្យយើងពិចារណា នៅក្នុងជីវិតរបស់យើងសព្វថ្ងៃ យើងធ្វើដូចម្តេចដើម្បីរស់នៅជាគ្រីស្តបរិស័ទដែលកំពុងត្រៀមខ្លួនទទួលការសង្គ្រោះសម្រាប់ជីវិតរបស់យើងផ្ទាល់ និងណែនាំឲ្យបងប្អូនមួយចំនួនអាចចូលរួមនៅក្នុងការសង្គ្រោះរបស់ព្រះអង្គជារឿងបន្ទាន់ យើងមិនចាំថ្ងៃស្អែក យើងចាប់ផ្តើមពីថ្ងៃនេះតទៅ។

យើងអធិដ្ឋាន ទូលអង្វរព្រះជាម្ចាស់ដើម្បីឲ្យរដូវ៤០ថ្ងៃនេះរួមជាមួយបងប្អូនគ្រីស្តបរិស័ទទាំងអស់ ឲ្យយើងអាចបង្កើតព្រះសហគមន៍ដែលពោរពេញដោយមនុស្សថ្មី ជាមនុស្សដែលពោរពេញដោយសេចក្តីសង្ឃឹម ជាមនុស្សដែលឈរឡើងវិញរួមជាមួយព្រះយេស៊ូ ដែលណែនាំឲ្យយើងចេញពីសេចក្តីស្លាប់ ដើម្បីចូលនៅក្នុងជីវិត មិនមែនជាជីវិតលើផែនដីនេះគឺជីវិតនៅស្ថានបរមសុខ។ អាម៉ែន៕